**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ ប៣៨២/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃសម័យប្រជុំលើកទី៣ នៃកិច្ចពិគ្រោះយោបល់ទ្វេភាគី រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ស៊ុន សុវណ្ណា** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងលោក Benoît GUIDÉE ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេស នៃសាធារណរដ្ឋបារាំង បានធ្វើជាសហប្រធានកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចពិគ្រោះយោបល់នេះបានប្រព្រឹត្តទៅក្នុងបរិយាកាសនៃការជឿទុកចិត្តគ្នា មិត្តភាពជិតស្និទ្ធ និងការសហការ។

ក្នុងឱកាសកិច្ចពិគ្រោះយោបល់នេះ **ឯកឧត្តមរដ្ឋលេខាធិការ** និង**លោក** Benoît GUIDÉE បានវាយតម្លៃខ្ពស់លើទំនាក់ទំនងជាដៃគូប្រវត្តិសាស្ត្រប្រកបដោយទំនុកចិត្ត ការគោរពគ្នាទៅវិញទៅមក និងជាប្រយោជន៍រួមដល់ប្រជាជននៃប្រទេសទាំងពីរ។ សហប្រធានទាំងពីរ បានពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដោយបានពិភាក្សាលើវិស័យអាទិភាពនានាដែលមានស្រាប់ និងស្វែងរកកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែម ក្នុងគោលបំណងកសាងភាពជាដៃគូឱ្យកាន់តែរឹងមាំ ស្វាហាប់ និងយូរអង្វែងបន្ថែមទៀត ដើម្បីជាផលប្រយោជន៍រួម។ សហប្រធានទាំងពីរ បានពិភាក្សាផ្លាស់ប្តូរយោបល់លើទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្មនិងវិនិយោគ វិស័យការពារជាតិនិងសន្តិសុខ បេតិកភណ្ឌវប្បធម៌ សុខាភិបាល អប់រំ ព្រមទាំងបញ្ហា ក្នុងតំបន់ និងអន្តរជាតិ។

នៅក្នុងក្របខ័ណ្ឌនយោបាយ **ឯកឧត្តមរដ្ឋលេខាធិការ** បានសម្តែងក្តីពេញចិត្តចំពោះការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនដងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានអះអាងអំពីការត្រៀមរួចជាស្រេចរបស់កម្ពុជាក្នុងការទទួលដំណើរទស្សនកិច្ចរបស់ឥស្សរៈជនជាន់ខ្ពស់បារាំងមកកម្ពុជា ដើម្បីផ្តល់ជាសន្ទុះថ្មីដល់ទំនាក់ទំនងកម្ពុជា-បារាំង ក្នុងគោលបំណងសម្រេចបានភាពជាដៃគូយុទ្ធសាស្ត្រនៅឆ្នាំ២០២៦។ **លោក** Benoît GUIDÉE បានបង្ហាញទស្សនៈស្រដៀងគ្នាចំពោះការរីកចម្រើនទំនាក់ទំនងនយោបាយរវាងប្រទេសទាំងពីរ និងបានជម្រាបជូន អំពីគម្រោងទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ផងដែរ។ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការលើកកម្ពស់ទំនាក់ទំនងទ្វេភាគី នៃភាពជាដៃគូយុទ្ធសាស្ត្រ ដែលជាស្នូលនៃកម្មវត្ថុក្នុងការសម្រេចគោលដៅរួមទៅអនាគត ក៏ដូចជាស្ពាន

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ក្នុងការតភ្ជាប់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនានា។ ភាគីទាំងពីរ ក៏បានផ្តល់មតិទៅលើផែនទីបង្ហាញផ្លូវរួមសម្រាប់កិច្ចសហប្រតិបត្តិការ ដែលជាមូលដ្ឋានគ្រឹះក្នុងការចង្អុលបង្ហាញមាគ៌ាសម្រាប់ទំនាក់ទំនងទ្វេភាគីនាពេលខាងមុខ។

សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ ភាគីទាំងពីរបានសម្តែងមតិរួមគ្នាលើសារៈសំខាន់នៃការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការការពារជាតិទ្វេភាគី។ **លោក Benoît GUIDÉE** បានបង្ហាញនូវការគាំទ្រដល់កម្ពុជាក្នុងការហ្វឹកហ្វឺន និងកសាងសមត្ថភាពកងកម្លាំងរក្សាសន្តិភាពរបស់កម្ពុជា ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ។ ជាការឆ្លើយតប **ឯកឧត្តមរដ្ឋលេខាធិការ** បានកោតសរសើរ និងសម្តែងការអរគុណដល់រដ្ឋាភិបាលបារាំង ដែលបានបន្តគាំទ្រកម្ពុជាក្នុងការពង្រឹងទាំងផ្នែកបច្ចេកទេស សមត្ថភាព និងភាសាដល់កងកម្លាំងមួកខៀវកម្ពុជា។ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានស្វាគមន៍បារាំងចំពោះការបន្តកិច្ចសហប្រតិបត្តិការក្នុងវិស័យដោះមីននៅកម្ពុជា ជាពិសេសការរួមចំណែកដ៏សំខាន់ក្នុងការសម្រេចឱ្យបាននូវ គោលដៅ «**កម្ពុជាគ្មានមីន នៅឆ្នាំ២០៣០**»។ ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរយោបល់ក្នុងន័យស្ថាបនាលើកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ និងការអនុវត្តច្បាប់ដែលជាអាទិភាពរួម ព្រមទាំងកិច្ចសហការកាន់តែជិតស្និទ្ធ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការចែករំលែកព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ។

ក្នុងវិស័យកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មនិងវិនិយោគ **ឯកឧត្តមរដ្ឋលេខាធិការ** បានសម្តែងនូវអំណរគុណចំពោះភាពជាដៃគូសហប្រតិបត្តិការយូរអង្វែងរបស់រដ្ឋាភិបាលបារាំង ក្នុងការបន្តគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៣ មក តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD)។ ការគាំទ្រនេះផ្តោតជាពិសេសលើគម្រោងទឹកស្អាត កសិកម្ម ថាមពលបៃតង បរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធជាដើម។ **លោក Benoît GUIDÉE** បានលើកឡើងអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់របស់កម្ពុជាដែលកំពុងស្ថិតនៅលើមាគ៌ាដ៏ច្បាស់លាស់ ក្នុងការចាកចេញពីស្ថានភាពនៃប្រទេសមានការអភិវឌ្ឍតិចតួចនាប៉ុន្មានឆ្នាំខាងមុខនេះ។ សហប្រធានទាំងពីរ ក៏បានលើកឡើងនូវថាមវន្តនៃការផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ តាមរយៈវត្តមានក្រុមហ៊ុនធំៗ និងវិនិយោគិនបារាំងនៅកម្ពុជា។ ភាគីទាំងពីរក៏បានគូសបញ្ជាក់អំពីការលើកកម្ពស់ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និងនីតិវិធីនានាក្នុងកិច្ចសហប្រតិបត្តិការពន្ធគយ ទោះនៅក្នុងកាលៈទេសៈនៃបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃក៏ដោយ។

កិច្ចពិគ្រោះយោបល់នេះ ក៏បានរំលេចអំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យវប្បធម៌ និងបេតិកភណ្ឌ ក្នុងភាពជាដៃគូយូរអង្វែង ដើម្បីការថែរក្សា និងការអភិរក្សតំបន់បេតិកភណ្ឌពិភពលោកនៅកម្ពុជា។ **ឯកឧត្តមរដ្ឋលេខាធិការ** បានកោតសរសើរ និងថ្លែងអំណរគុណចំពោះគម្រោងជួសជុលសារមន្ទីរជាតិនៅទីក្រុងភ្នំពេញ ក៏ដូចជាគម្រោងនៃកិច្ចសហប្រតិបត្តិការជាមួយសាលាបារាំងសម្រាប់ការសិក្សាអាស៊ី (EFEO) ជាដើម។ ទន្ទឹមនេះ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានសម្តែងការខកចិត្ត និងសោកស្តាយជាខ្លាំងអំពីការខូចខាតយ៉ាងធ្ងន់ធ្ងររបស់សម្បត្តិបេតិកភណ្ឌកម្ពុជា រួមមានប្រាសាទតាក្របី និងប្រាសាទព្រះវិហារ ដែលបណ្តាលមកពីការឈ្លានពានរបស់កងទ័ពថៃ ហើយបានស្នើសុំភាគីបារាំង បន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារបេតិកភណ្ឌជាប្រវត្តិសាស្ត្រ តែមួយគ្មានពីរ ដែលបាននិងកំពុងបំផ្លិចបំផ្លាញដោយកងទ័ពថៃ។

**លោក** Benoît GUIDÉE បានបញ្ជាក់ពីគាំទ្រ និងការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីនៅកម្ពុជា ក្នុងគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌហ្វ្រង់កូហ្វូនីអោយកាន់តែស៊ីជម្រៅ ដូចជាការរៀបចំព្រឹត្តិការណ៍នានា រួមមានភូមិហ្វ្រង់កូហ្វូនី (Francophonie Village) និងហ្វ្រង់កូតិច (Francotech) ជាដើម។

ក្នុងឱកាសកិច្ចប្រជុំពិគ្រោះខាងលើនេះផងដែរ សហប្រធានទាំងពីរ បានឯកភាពលើតម្រូវការក្នុងការពង្រឹងធនធានមនុស្សតាមរយៈការអប់រំឧត្តមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍជំនាញឌីជីថល ក៏ដូចជាបន្តកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល និងវិស្វកម្ម។ ភាគីទាំងពីរក៏បានបង្ហាញនូវការប្តេជ្ញាចិត្តយូរអង្វែងរបស់ខ្លួនក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌ និងគាំទ្រដល់ការសន្ទនាដោយសន្តិវិធី និងស្ថិរភាពដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគី ភាគីទាំងពីរ ក៏បានពិភាក្សាអំពីបញ្ហាតំបន់ និងពិភពលោក ក៏ដូចជាការវិវត្តចុងក្រោយនៃជម្លោះព្រំដែនកម្ពុជា-ថៃ។ ភាគីកម្ពុជា ក៏បានបង្ហាញពីការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជាទៅលើការគោរពបទឈប់បាញ់ និងសេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ ដែលបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួ កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៥ ប្រកបដោយសុឆន្ទៈខ្ពស់បំផុត។

កិច្ចប្រជុំពិគ្រោះយោបល់នយោបាយលើកទី៣ រវាងកម្ពុជា-បារាំង បានបញ្ចប់ដោយជោគជ័យ និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងអោយឃើញពីការជឿទុកចិត្តគ្នាទៅវិញទៅមកយ៉ាងរឹងមាំនៅកម្រិតនយោបាយខ្ពស់បំផុត និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងប្រទេសទាំងពីរ។

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥